ក្រុមប្រឹក្សាអាជ្ញាកណ្តាល
មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី
សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣) ២២០ ៧៩៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**លេខ និងឈ្មោះសំណុំរឿង : ៧១/០៥ - ភ្នំពេញ ហ្គាមិន**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **វ៉ែន ពៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ភ្នំពេញ ហ្គាមិន**

អាសយដ្ឋាន : ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ៤២៥ ៦២០ ទូរសារលេខ : ០២៣ ២១៩ ៦០៩

**តំណាងភាគីនិយោជក :**

| | |
|---|---|
| ១-កញ្ញា សែម សុគន្ធា | ប្រធានរដ្ឋបាលក្រុមហ៊ុន |
| ២-កញ្ញា ឡោ ប៊ុនថាវីរ | រដ្ឋបាលក្រុមហ៊ុន |
| ៣-លោក ជាតិ ខេមរា | មន្ត្រី **GMAC** |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហព័ន្ធសហជីពសេរីពលករខ្មែរ និង សហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ភ្នំពេញ ហ្គាមិន

អាសយដ្ឋាន : ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៦៨៨ ១៩១ ទូរសារ: គ្មាន

**តំណាងកម្មករនិយោជិត :**

១- លោក សុខ រ៉ាវុធ ប្រធានសហព័ន្ធសហជីពសេរីពលករខ្មែរ

២- លោក ស្រី សិរីវឌ្ឍនា លេខាធិការសហព័ន្ធសហជីពសេរីពលករខ្មែរ

៣- លោក ទុយ ធួន អនុប្រធានសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ភ្នំពេញ ហ្គាមិន

៤- លោក គឹម ដារ៉ា ហិរញ្ញិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ភ្នំពេញ ហ្គាមិន

៥- លោក ស៊ីម ធី ទីប្រឹក្សាសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ភ្នំពេញ ហ្គាមិន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

យោងតាមកំណត់ហេតុក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ចំណុចបញ្ហាមិនសះជាខាងក្រោម ជាការទាមទាររបស់ភាគីកម្មករនិយោជិតនៃសំណុំរឿងវិវាទ:

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងកន្លែងបំបៅដោះកូន ឬបើក្រុមហ៊ុនគ្មានលទ្ធភាពធ្វើ សុំឱ្យក្រុមហ៊ុនផ្តល់ម៉ោងទឹកដោះគោ ឬលុយជំនួសក៏បាន ដោយហេតុថា ការទាមទារនេះ គឺជាសិទ្ធិដែលមានចែងក្នុងច្បាប់ស្តីពីការងារ ។ ចំណែកក្រុមហ៊ុនមិនឯកភាពតាមសំណូមពរទេ ព្រោះក្រុមហ៊ុនមានទីធ្លាតូច សូម្បីតែបន្ទប់ស្នាក់នៅរបស់មេកន្ត្រៃក៏គ្មានដែរ ហើយបញ្ហាដែលជួយជាថវិកា ឬផ្តល់ម៉ោងទឹកដោះគោដល់កម្មការិនីដែលមានកូន ក៏ក្រុមហ៊ុនគ្មានលទ្ធភាពជួយដែរ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាម ជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៦០៧ ក.ក.ប.វ/អក/វ.ក ចុះថ្ងៃទី០៨ ខែវិច្ឆកា ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥ ( វេលាម៉ោង១៤:០០ ដល់ម៉ោង១៧:០០ នាទី ល្ងាច)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំប្រជុំមួយដើម្បីផ្សះផ្សាវិវាទរវាងភាគីកម្មករនិយោជិតនៅក្រុមហ៊ុន ភ្នំពេញ ហ្គាមិន និងភាគីក្រុមហ៊ុន ភ្នំពេញ ហ្គាមិន ។ ភាគីកម្មករបានទាមទារឱ្យក្រុមហ៊ុនត្រូវតែសាងសង់បន្ទប់បំបៅកូន និងទារកដ្ឋាន ។ មន្ត្រីផ្សះផ្សាវិវាទបានព្យាយាមផ្សះផ្សាវិវាទនេះ ប៉ុន្តែភាគីទាំងពីរមិនបានឈានដល់ការព្រមព្រៀងទេ ។ ដូច្នេះ វិវាទការងារនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៥ ។ បន្ទាប់ពីបានទទួលសំណុំរឿង លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីទាំងពីរមកចូលរួមសវនាការដែលប្រព្រឹត្តិទៅនៅថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០០៥ ។

ភាគីទាំងពីរបានមកចូលរួមនៅថ្ងៃសវនាការ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមផ្សះផ្សាវិវាទនេះជាបន្តទៀត ប៉ុន្តែភាគីទាំងពីរមិនបានព្រមព្រៀងគ្នាលើបញ្ហានេះទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការសម្រេច ដោយផ្អែកលើអង្គហេតុដូចខាងក្រោម :

## អង្គហេតុ

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ជូន កញ្ញា សែម សុគន្ធា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥

២- លិខិតចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ក្រុមហ៊ុន ភ្នំពេញ ហ្គាមិន ជំរាបជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីដំណោះស្រាយបញ្ហាសង់ទារកដ្ឋាន និងកន្លែងបំបៅកូន

៣- របាយការណ៍នៃការកាត់ប្រាក់ភាគទានសហជីព ជូនសហជីពសេរីពលករខ្មែរ សំរាប់ខែតុលា ឆ្នាំ២០០៥

៤- របាយការណ៍នៃការកាត់ប្រាក់ភាគទានសហជីព ជូនសហជីពសេរីកម្មករ សំរាប់ខែតុលា ឆ្នាំ២០០៥

៥- ប្លង់ទីតាំងក្រុមហ៊ុន ភ្នំពេញ ហ្គាមិន ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- លិខិតស្នើសុំឱ្យដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ភ្នំពេញ ហ្គាមិន លេខ ១៧៣៦ ក.ក.ប.វ ឯកឧត្តម ញ៉ែប ប៊ុនជិន រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

២- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភ្នំពេញ ហ្គាមិន លេខ ៦០៧ ក.ក.ប.វ /វ.ក របស់លោក កុយ ទេពដារារ៉ុធ ប្រធាននាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០០៥ ។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ៨៦៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ៨៦២ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

- ក្រុមហ៊ុន ភ្នំពេញ ហ្គាមិន មានជួលកម្មករនិយោជិតស្ត្រីចំនួនប្រហែល ៧០០ នាក់ និង កម្មករនិយោជិតបុរសចំនួនប្រហែល ១៥៣ នាក់ ។ ក្នុងចំណោមកម្មករនិយោជិតស្ត្រីចំនួន ៧០០នាក់ នេះ មានប្រហែលពី ៣០ ទៅ ៤០នាក់ ជាកម្មករនិយោជិតដែលមានកូនក្នុងអំឡុងពេលចាប់ផ្តើមពីខែមករា ឆ្នាំ២០០៥។

- ក្រុមហ៊ុនមិនមានបន្ទប់បំបៅកូន និងទារកដ្ឋានទេ ។ ក្នុងការអនុវត្តជាក់ស្តែង ក្រុមហ៊ុនអនុញ្ញាតឱ្យកម្មការិនីឈប់សម្រាកកន្លះម៉ោងនៅចុងម៉ោងឈប់សម្រាកអាហារថ្ងៃត្រង់ និង កន្លះម៉ោងនៅដើម្បីម៉ោងចូលធ្វើការងារពេលរសៀលដើម្បីឱ្យពួកគេអាចទៅបំបៅកូនបាន ។ ម៉ោងឈប់សម្រាកនេះចាប់ផ្តើមពីម៉ោង១០:៣០នាទី ដល់ម៉ោង១២:៣០នាទី ។ កម្មការិនីបានទទួលសិទ្ធិឈប់សម្រាកនេះ ដោយបានទៅផ្ទះ ហើយបំបៅកូនរបស់ពួកគេនៅផ្ទះ។

- ក្រុមហ៊ុនមិនមានលទ្ធភាពសាងសង់ទារកដ្ឋានទេ ដោយហេតុថា ទីតាំងក្រុមហ៊ុនចង្អៀត ហើយត្រូវប្រើប្រាស់រួមគ្នាជាមួយក្រុមហ៊ុន ហ្គោល លីដា ។

## ហេតុផលនៃសេចក្តីសំរេច

នៅក្នុងករណីនេះ ក្រុមហ៊ុន ភ្នំពេញ ហ្គាមិន មានកម្មករស្ត្រីចំនួនប្រមាណជាង ៧០០ នាក់ ។ ក្រុមហ៊ុននេះ មិនទាន់មានរៀបចំបន្ទប់សំរាប់បំបៅកូន និងទារកដ្ឋាននៅឡើយទេ ប៉ុន្តែ ក្រុមហ៊ុនបានអនុញ្ញាតឱ្យស្ត្រីមានកូនតូចឈប់មួយម៉ោងក្នុងមួយថ្ងៃ ដើម្បីបំបៅកូន ។ នៅក្នុងរឿងនេះ កម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃទឹកដោះគោទៅឱ្យម្តាយ ដែលផ្តល់កំណើតឱ្យទារកដែលបំបៅកូនរបស់ពួកគេ ប្រសិនបើក្រុមហ៊ុនមិនមានលទ្ធភាពសាងសង់បន្ទប់បំបៅកូន និងទារកដ្ឋានទេនោះ ។

មាត្រា ១៨៦ នៃច្បាប់ស្តីពីការងារចែងថា នាយកសហគ្រាសទាំងឡាយដែលប្រើស្ត្រីចាស់ក្តី ក្មេងក្តី ចំនួនយ៉ាងតិច ១០០ នាក់ ត្រូវរៀបចំបន្ទប់សំរាប់បំបៅកូនមួយនៅក្នុងគ្រឹះស្ថាន ឬនៅជិតនោះ ហើយនិងទារកដ្ឋានមួយផង ។ ក្នុងករណីដែល សហគ្រាសមិនមានលទ្ធភាពរៀបចំបន្ទប់សំរាប់បំបៅកូន និងទារកដ្ឋាន សំរាប់ទទួលកុមារអាយុលើសពី១៨ខែផ្ទាល់បានទេ នារីជាកម្មករនិយោជិតអាចផ្ញើកូនរបស់ខ្លួននៅទារកដ្ឋានណាមួយ ដោយនិយោជកជាអ្នកចេញសោហ៊ុយថែទារកនោះ ។ ចំណែកមាត្រា ១៨៧ បានចែងថា " *ប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ នឹងកំណត់លក្ខខណ្ឌសំរាប់រៀបចំអោយមានអនាម័យ និងត្រួតពិនិត្យបន្ទប់បំបៅកូន និងទារកដ្ឋាននោះ* " ។

មាត្រា ១៨៦ នៃច្បាប់ស្តីពីការងារខាងលើ បានផ្តល់អោយភាគីនិយោជកមានជម្រើសពីរ : ទីមួយគឺសាងសង់បន្ទប់បំបៅកូន និងទារកដ្ឋាន ឬ ទីពីរ គឺចេញសោហ៊ុយឱ្យកម្មការិនីដែលមានកូន មានអាយុលើសពី១៨ខែសំរាប់ឱ្យគាត់យកទៅជួលអ្នកណាម្នាក់ឱ្យមើលថែទាំកូន ។ មាត្រានេះ ចែងច្បាស់អំពីអ្វីដែលនិយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិត មានរៀបចំបន្ទប់សំរាប់បំបៅកូន និងទារកដ្ឋាន ឬ ចេញសោហ៊ុយសំរាប់ឱ្យម្តាយកុមារជួលកន្លែងផ្ញើកូន និងមនុស្សឱ្យមើលថែទាំកូន (សូមមើលសំណុំរឿង លេខ ៨៣/០៤ ក្រុមហ៊ុន កាត់ដេរ ជូន តិចស្តាយ៏) ។

ប៉ុន្តែក្នុងរឿងនេះ កម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃទឹកដោះគោទៅឱ្យម្តាយ ដែលផ្តល់កំណើតឱ្យទារក ដែលបំបៅកូនរបស់ពួកគេ ប្រសិនបើក្រុមហ៊ុនមិនមានលទ្ធភាពសាងសង់បន្ទប់បំបៅកូន និងទារកដ្ឋានទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ច្បាប់ការងារមិនអនុញ្ញាតឱ្យមានការផ្តល់ទឹកដោះគោ ឬបង់ប្រាក់ ជំនួសការសង់បន្ទប់បំបៅកូនទេ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលក្រុមហ៊ុន សាញ់វីល លេខ ៦៣/០៤ និង ក្រុមហ៊ុន ស៊ីធីញូ លេខ៦៨/០៤ ) ។ ស្មារតីនៃច្បាប់នេះ គឺលើកទឹកចិត្តឱ្យម្តាយបំបៅកូន ដោយទឹកដោះម្តាយ ដែលជាគុណប្រយោជន៏ដ៏ធំធេងសំរាប់សុខភាពរបស់ទារក ជាជាងទឹកដោះគោកំប៉ុង ។ ហេតុនេះហើយទើបមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ តម្រូវឱ្យនិយោជកផ្តល់ពេលវេលាជូនដល់ម្តាយសំរាប់បំបៅដោះកូនក្នុងរយៈពេលមួយម៉ោងក្នុងមួយថ្ងៃដើម្បីបំបៅកូនខ្លួនក្នុងពេលម៉ោងធ្វើការ ។ ការផ្តល់ម្ហូបអាហារ និងការគាំទ្រផ្សេងៗទៀត ដែលចាំបាច់សម្រាប់ការរស់នៅ និងការអប់រំកូនៗរបស់ខ្លួនមានចែងច្បាស់ក្នុង មាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ និងមាត្រា ១១៥ ច្បាប់អាពាហ៏ពិពាហ៏ និងគ្រួសារ ឆ្នាំ ១៩៨៩ ។ មាត្រាទាំងនេះតម្រូវឱ្យ

មាតាបិតាផ្តល់ម្ហូបអាហារ និង ការគាំទ្រផ្សេងៗទៀត ដែលចាំបាច់សម្រាប់ការរស់នៅ និងការអប់រំកូនៗរបស់ខ្លួនអោយក្លាយជាពលរដ្ឋល្អ ។ សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតអោយក្រុមហ៊ុនផ្តល់ថ្លៃទឹកដោះគោទៅឱ្យម្តាយនោះមិនត្រឹមត្រូវទេ ព្រោះនេះជាកាតព្វកិច្ចរបស់មាតាបិតា ដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាកូន ។ កាតព្វកិច្ចនេះមិនអាចផ្ទេរទៅអោយអ្នកដទៃបានទេ (ដូចជា និយោជកក្នុងរឿងនេះ) ។

ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចតាមផ្លូវច្បាប់ត្រូវរៀបចំបន្ទប់បំបៅកូន និងទារកដ្ឋានមួយក្រោមការត្រួតពិនិត្យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ ត្រូវចេញសោហ៊ុយថែរក្សាទារក តាមវិក្កយប័ត្រដែលកម្មករជាស្ត្រីបានយកកូនរបស់ខ្លួនទៅផ្ញើនៅទារកដ្ឋានខាងក្រៅ ។ (សូមមើលសំណុំរឿងលេខ ៥៣/០៤- ក្រុមហ៊ុន គង់ ហុង សំណុំរឿងលេខ ៩៤/០៤- ក្រុមហ៊ុន អ៊ុឌីនីធី អ៊ីភែរីល និង សំណុំរឿងលេខ ១០៧/០៤- ក្រុមហ៊ុន ហ្សាក់ ស៊ីនតិច ) ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេច :

## បង្គាប់

បង្គាប់អោយនិយោជករៀបចំបន្ទប់បំបៅកូន និងទារកដ្ឋានមួយនៅក្នុងក្រុមហ៊ុនក្រោមការត្រួតពិនិត្យរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ឬត្រូវចេញសោហ៊ុយថែរក្សាទារក ដែលមានអាយុលើសពី ១៨ ខែ តាមវិក្កយប័ត្រដែលកម្មករជាស្ត្រីបានយកកូនរបស់ខ្លួនទៅផ្ញើនៅទារកដ្ឋានខាងក្រៅ ចាប់ពីសេចក្តីបង្គាប់នេះចូលជាធរមាន។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **យូ សួនធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------